# មេរោគវីរុសផ្លូវដង្ហើម (Respiratory Syncytial Virus, RSV)

Tacoma-Pierce County
Health Department
*Healthy People in Healthy Communities*

**វីរុស RSV បង្កឱ្យកើតជំងឺផ្តាសាយនិងឆ្លងមេរោគផ្លូវដង្ហើមផ្សេងទៀត ដូចជាជំងឺរលាកសួត ជាដើម។**

វីរុស RSV អាចបង្កឱ្យកើតជំងឺធ្ងន់ធ្ងរចំពោះទារក មនុស្សពេញវ័យ ចាប់ពីអាយុ 75 ឆ្នាំឡើងទៅ និងមនុស្សគ្រប់វ័យដែលមានប្រព័ន្ធ ការពាររាងកាយទន់ខ្សោយ និងមានជំងឺរ៉ាំរ៉ៃមួយចំនួន។

## រោគសញ្ញាចំពោះកុមារនិងមនុស្សពេញវ័យ

- ហៀរសំបោរ
- ក្អក
- កណ្តាស់
- គ្រុនក្តៅ
- ដកដង្ហើមតឹងដូចកើតហឺត
- ចំណង់អាហារតិច



## រោគសញ្ញាចំពោះទារក

- មារអារម្មណ៍មួម៉ៅ
- មិនសូវបៅ
- អស់កម្លាំងខុសពីធម្មតា
- ក្អកឬពិបាកដកដង្ហើម



## របៀបដែលមេរោគវីរុស RSV រាលដាល



នៅពេលមនុស្សដែលមានផ្ទុកវីរុស RSV ក្អក ឬកណ្តាស់



នៅពេលអ្នកប៉ះផ្ទៃដែលមានមេរោគវីរុសរួចប៉ះមុខរបស់អ្នក

### ការពិតអំពីមេរោគវីរុស RSV

- មនុស្សដែលមានផ្ទុកមេរោគវីរុស RSV អាចឆ្លងមុនពេលចេញរោគសញ្ញា
- មេរោគវីរុសអាចរស់នៅលើផ្ទៃបានច្រើនម៉ោងនិងនៅលើដៃជាង 30 នាទី
- ជាធម្មតា មេរោគវីរុស RSV រីករាលដាលក្នុងរដូវរងានិងរដូវផ្ការីក ប៉ុន្តែអាចកើតឡើងគ្រប់ពេលវេលា។

## សូមការពារខ្លួនអ្នកនិងអ្នកដទៃ

- លាងដៃរបស់អ្នកញឹកញាប់ជាមួយសាប៊ូនិងទឹកក្តៅឧណ្ហៗ។
- គ្របមាត់នៅពេលក្អកនិងកណ្តាស់ដោយប្រើក្រដាសជូតមាត់ឬកែងដៃ។
- សម្អាតនិងអនាម័យតាមលើផ្ទៃកខ្វក់
- ស្នាក់នៅផ្ទះពេលអ្នកឈឺ



## ការចាក់ថ្នាំបង្ការរោគ ផ្តល់ការការពារដ៏ល្អបំផុត

- អំឡុងពេលមានផ្ទៃពោះ ឬសម្រាប់ទារកអាយុក្រោម 8 ខែ
- កុមារដែលទើបចេះដើរតេះតះដែលមានហានិភ័យខ្ពស់
- មនុស្សពេញវ័យអាយុពី 50-74 ឆ្នាំដែលមានហានិភ័យខ្ពស់
- មនុស្សពេញវ័យចាប់ពីអាយុ 75 ឆ្នាំឡើងទៅ



## ការថែទាំមនុស្សដែលមានផ្ទុកវីរុស RSV

មនុស្សដែលមានមេរោគ RSV ជាធម្មតាជាសះស្បើយឡើងវិញក្នុងរយៈពេល 1 ឬ 2 សប្តាហ៍។ សូមសម្រាកនិងទទួលទានទឹកឱ្យបានច្រើន។



តើអ្នកគួរទៅមន្ទីរសង្គ្រោះបន្ទាន់ ទៅមន្ទីរមើលជំងឺបន្ទាន់ ទៅជួបអ្នកផ្តល់សេវាថែទាំសុខភាព ឬមើលថែខ្លួននៅផ្ទះដែរឬទេ?

អ្នកអាចប្រើសំណួរទាំងនេះដើម្បីធ្វើការសម្រេចចិត្ត៖

**marybridge.org/for-patients-families/where-to-seek-care**

**ដើម្បីស្វែងយល់បន្ថែម សូមពិភាក្សាគ្នាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ឬចូលទៅគេហទំព័រ tpchd.org/protect។**

Khmer | Rev. Aug. 26, 2025